## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
## ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីសម្រេចកែសម្រួលលើកទី៥

**លើឯកសារអាជ្ញាប័ណ្ណផលិតកម្មលេខ ១២៦ឯអ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៦**

**សម្រាប់ឱ្យក្រុមហ៊ុន អេស.អេច.ស៊ី (ខេមបូឌា) អ៊ិនធើណេសិនណល ភីធីអ៊ី អិលធីឌី**

**ធ្វើសេវាកម្មផលិតកម្មអគ្គិសនីនៅរាជធានីភ្នំពេញ និងទីរួមខេត្តរតនគិរី**

# DECISION ON FIFTH REVISION

**OF THE GENERATION LICENSE DOCUMENT Nº 126LD DATED FEBRUARY 8, 2006**

**FOR S.H.C (CAMBODIA) INTERNATIONAL PTE LTD**

**FOR PROVIDING ELECTRIC POWER GENERATION SERVICE**

**AT PHNOM PENH CITY AND RATTANAKIRI PROVINCIAL TOWNS.**

**ថ្ងៃទី... ខែ... ឆ្នាំ ២០០៩**

**…., 2009**

# ព្រះរាជាណាចក្រកម្ពុជា

**KINGDOM OF CAMBODIA**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**NATION RELIGION KING**

## អាជ្ញាធរអគ្គិសនីកម្ពុជា

**ELECTRICITY AUTHORITY OF CAMBODIA**

លេខ : -០៩-អអក

## សេចក្តីសម្រេចកែសម្រួលលើកទី៥
## លើឯកសារអាជ្ញាប័ណ្ណផលិតកម្មលេខ ១២៦ឯអ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៦
## សម្រាប់ក្រុមហ៊ុន អេស.អេច.ស៊ី (ខេមបូឌា) អ៊ិនធើណេសិនណល ភីធីអ៊ី អិលធីឌី

## DECISION ON THIRD REVISION
## of the Generation License Document Nº 126LD dated February 08, 2006
## for S.H.C (CAMBODIA) INTERNATIONAL PTE LTD

## អាជ្ញាធរអគ្គិសនីកម្ពុជា

**ELECTRICITY AUTHORITY OF CAMBODIA**

-អនុវត្តតាមមាត្រា ៧ និង ៣០របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១។

- In exercise of the powers conferred by Article 7 and 30 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03 dated February 2, 2001.

-យោងឯកសារអាជ្ញាប័ណ្ណផលិតកម្មលេខ ១២៦ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញឱ្យក្រុមហ៊ុន អេស.អេច.ស៊ី (ខេមបូឌា) អ៊ិនធើណេសិនណល ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៦។

- In accordance with the Generation License Document Nº 126LD issued by Electricity Authority of Cambodia on February 8, 2006 to SHC (Cambodia) International Pte Ltd.

-យោងពាក្យស្នើសុំកែសម្រួលអាជ្ញាប័ណ្ណផលិតកម្មនៅទីរួមខេត្តរតនគីរីរបស់ ក្រុមហ៊ុន អេស.អេច.ស៊ី (ខេមបូឌា) អ៊ិនធើណេសិនណល ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩ ។

- In accordance with the Application for revision of Generation License of S.H.C (Cambodia) International Pte Ltd of provincial town of Rattanakiri dated May 04, 2009.

-យោងកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនីនៅទីរួមខេត្តរតនគីរី រវាង អគ្គិសនីកម្ពុជា និងក្រុមហ៊ុន អេស.អេច.ស៊ី (ខេមបូឌា) អ៊ិនធើណេ សិនណល ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩ ។

- In accordance with the Power Purchase Agreement in Rattanakiri between Electricité du Cambodge and S.H.C (Cambodia) International Pte Ltd dated May 04, 2009.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី... ខែ... ឆ្នាំ២០០៩ ដល់ថ្ងៃទី... ខែ.... ឆ្នាំ២០០៩ ។

- In accordance with the consultation with concerned parties and public, made from …, 2009 to …., 2009.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី... ចុះថ្ងៃទី... ខែ... ឆ្នាំ២០០៩ ។

- In accordance with the decision of Electricity Authority of Cambodia's Session Nº … dated ….., 2009.

# សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ១២៦ឯអ ដែលបានចេញឱ្យក្រុមហ៊ុន **អេស.អេច.ស៊ី (ខេមបូឌា) អ៊ិនធើណេសិនណល ភីធីអ៊ី អិលធីឌី** ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៦ ដើម្បីផ្តល់សិទ្ធិដូចតទៅ : | **Article 1**<br>To revise License Nº 126 LD granted **S.H.C (Cambodia) International Pte Ltd** dated February 08, 2006 to provide as follows: |
| (១) បន្តផ្តល់សេវាកម្មផលិតកម្មអគ្គិសនី ពីរោងចក្រផលិតអគ្គិសនីដើរដោយប្រេងដ្យេស៊ែល ដែលមានអានុភាពតម្លើងសរុប 13.639MVA ដែលមានទីតាំងនៅក្នុងរោងចក្រអគ្គិសនីទី១ ទី៣ និងទី៥ របស់ក្រុមហ៊ុនអគ្គិសនីកម្ពុជានៅរាជធានីភ្នំពេញ សម្រាប់ផ្គត់ផ្គង់អគ្គិសនីអានុភាព 8MW ឱ្យប្រព័ន្ធចែកចាយរបស់ក្រុមហ៊ុនអគ្គិសនីកម្ពុជា អនុលោមតាមកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី ដែលចុះហត្ថលេខារវាង **អ្នកកាន់អាជ្ញាប័ណ្ណ** និង **អគ្គិសនីកម្ពុជា** នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៧ (បន្ទាប់ពីនេះទៅហៅថា **កិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី**) រហូតដល់ពេលបញ្ចប់អាណត្តិនៃកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនីនេះ ។ | (1) to continue to provide electric power generation services from the Diesel power plant with the total installed capacity of 13.639 MVA located in the EDC's Power Plant Nº 1, Nº 3 and Nº 5 in Phnom Penh for supplying 8MW of electricity to distribution system of Electricité du Cambodge in accordance to the Power Purchase Agreement on May 09, 2007 between **Licensee** and **Electricité du Cambodge** (hereinafter referred to as **PPA**) until the termination of the term of this Power Purchase Agreement. |
| (២) បន្តផ្តល់សេវាកម្មផលិតកម្មអគ្គិសនី ពីរោងចក្រផលិតអគ្គិសនីដើរដោយប្រេងដ្យេស៊ែលមានអានុភាពតម្លើងសរុប 1.00MVA ដែលមានទីតាំងនៅក្នុងរោងចក្រអគ្គិសនី ស្ថិតក្នុងភូមិថ្លុងជង ឃុំអូរជុំ ស្រុកអូរជុំ ខេត្តរតនគិរី សម្រាប់ផ្គត់ផ្គង់អគ្គិសនីអានុភាព 0.4MW ឱ្យប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជា អនុលោមតាមកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី ដែលចុះហត្ថលេខា រវាង **អ្នកកាន់អាជ្ញាប័ណ្ណ** និង **អគ្គិសនីកម្ពុជា** លេខ២៤១PEAC.អក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩ ។ | (2) to continue to provide electric power generation services from the Diesel power plant with the total installed capacity of 1.00 MVA located at Phum Thlongchung, Khum Or Chum, Srok Or Chum, Rattanakiri Province for supplying 0.4MW of electricity to distribution system of Electricité du Cambodge in accordance to the Power Purchase Agreement No.241 PEAC.EDC dated May 4, 2009 between **Licensee** and **Electricité du Cambodge**. |
| **ប្រការ២**<br>ឧបសម្ព័ន្ធទី១នៃឯកសារអាជ្ញាប័ណ្ណលេខ ១២៦ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The Schedule 1 of the license Nº 126L shall be replaced by new Schedule 1 attached here with. |
| **ប្រការ៣**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ១២៦ឯអ | **Article 3**<br>The other contents and conditions of the license |

| | |
|---|---|
| ត្រូវបិតនៅជាធរមានដដែល ។ | document Nº 126 LD shall remain unaltered and in force. |
| **ប្រការ៤** | **Article 4** |
| សេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ១២៦ឯអ ។ | This decision and the attached Schedules should be part of license Nº 126 LD. |
| **ប្រការ៥** | **Article 5** |
| សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងត្រូវបន្តនៅជាធរមានរហូតដល់ពេលបញ្ចប់អាណត្តិកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនីដែលមានបញ្ជាក់នៅក្នុងប្រការ១ខាងលើ លើកលែងតែត្រូវបានដកហូត ដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃសេចក្តីសម្រេចនេះ ។ | This decision shall come into force from the date of signing and shall continue to be in force until the end of the Terms of the Power Purchase Agreements specified in Article 1 above, unless revoked earlier in accordance with the conditions of this License. |
| **ប្រការ៦** | **Article 6** |
| អ្នកកាន់អាជ្ញាប័ណ្ណត្រូវតម្កល់ទុកសេចក្តីសម្រេចនេះ នៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ១២៦ឯអ ដែលបានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ១២៦ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | The licensee shall deposit this decision at the places, where the license document Nº 126 LD have been deposited in order that the deposited license document Nº 126 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០០៩

Phnom Penh, ….., 2009

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

**Chairman of EAC**

# ឧបសម្ព័ន្ធទី១
## មធ្យោបាយផលិតកម្មកំណត់ជាក់លាក់របស់អ្នកកាន់អាជ្ញាប័ណ្ណដែលកែសម្រួលជាថ្មី
## ក្នុងសម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជាលើកទី... ចុះថ្ងៃទី... ខែ... ឆ្នាំ២០០៩

# SCHEDULE 1
## FIXED IDENTIFIED GENERATING FACILITIES OF THE LICENSEE AS AMMENDED IN SESSION OF EAC N° … DATED ……, 2009

| | |
|---|---|
| **១ រោងចក្រអគ្គិសនីភ្នំពេញ** | **1. AT PHNOM PENH'S POWER PLANT** |
| **ក រោងចក្រអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **A. Licensee's Plant** |
| ១. រោងចក្រអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ជារោងចក្រអគ្គិសនីដើរដោយប្រេងម៉ាស៊ូតស៊ែលទំហំ 13.639 MVA ដែលមានទីតាំងនៅក្នុងរោងចក្រអគ្គិសនីទី១ ទី៣ និងទី៥ របស់ក្រុមហ៊ុនអគ្គិសនីកម្ពុជា នៅរាជធានីភ្នំពេញ សម្រាប់ផ្គត់ផ្គង់អគ្គិសនីឱ្យប្រព័ន្ធចែកចាយរបស់ក្រុមហ៊ុនអគ្គិសនីកម្ពុជាក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី ដែលចុះហត្ថលេខា រវាង **អ្នកកាន់អាជ្ញាប័ណ្ណ** និង ក្រុមហ៊ុន **អគ្គិសនីកម្ពុជា** នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៧។ | 1. The Licensee's Plant is of total capacity of 13.639 MVA, Diesel Power Plant located in the EDC's Power Plant N° 1, N° 3 and N° 5 in Phnom Penh for supplying of electricity to distribution system of Electricité du Cambodge in accordance with the PPA signed between **Licensee** and **Electricité du Cambodge** on May 09, 2007. |
| **ខ លក្ខណៈទូទៅនៃរោងចក្រ** | **B. General Specifications of the Plant** |
| ១. រោងចក្រអគ្គិសនីមានម៉ាស៊ីនសរុបចំនួន ១៨គ្រឿង មានអានុភាពតម្លើងសរុបចំនួន 13639 KVA រួមមាន ៖<br>-ម៉ាស៊ីនភ្លើងអានុភាពតម្លើង 619 kVA ចំនួន ២១គ្រឿង<br>-ម៉ាស៊ីនភ្លើងអានុភាពតម្លើង 640 kVA ចំនួន ១គ្រឿង | 1. The Plant consists of 18 diesel generator Units with the total installed capacity of 13639 KVA:<br>-21 diesel engines with installed capacity of 619 kVA each<br>-1 diesel engine with installed capacity of 640 kVA |
| ២. ប្រេងឥន្ធនៈប្រើប្រាស់សម្រាប់ដំណើរការរោងចក្រអគ្គិសនី គឺប្រេងម៉ាស៊ូតស៊ែល LDO ។ | 2. The normal fuel for the operation of the Power Plant shall be Light Distillate Oil (LDO). |
| **២ នៅរោងចក្រអគ្គិសនីខេត្តរតនគីរី** | **2. AT RATTANAKIRI'S POWER PLANT** |
| **ក រោងចក្រអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **A. Licensee's Plant** |
| ១. រោងចក្រអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ជារោងចក្រអគ្គិសនីដើរដោយប្រេងម៉ាស៊ូតស៊ែលអានុភាពតម្លើងសរុប 1.00 MVA ដែលមានទីតាំងនៅក្នុងរោងចក្រអគ្គិសនី ស្ថិតក្នុងភូមិថ្លុងជង ឃុំអូរជុំ ស្រុកអូរជុំ ខេត្តរតនគីរី សម្រាប់ផ្គត់ផ្គង់អគ្គិសនីឱ្យប្រព័ន្ធចែកចាយរបស់អគ្គិសនីកម្ពុជា ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី ដែលចុះហត្ថលេខារវាង **អ្នកកាន់អាជ្ញាប័ណ្ណ** និង **អគ្គិសនីកម្ពុជា** នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៩។ | 1. The Licensee's Plant is total installed capacity of 1.00 MVA, Diesel Power Plant located at Phum Thlongchung, Khum Or Chum, Srok Or Chum, Rattanakiri Province for supplying of electricity to distribution system of Electricité du Cambodge in accordance with the PPA signed between **Licensee** and **Electricité du Cambodge** on May 4, 2009. |
| **ខ លក្ខណៈទូទៅនៃរោងចក្រ** | **B. General Specifications of the Plant** |
| ១. រោងចក្រអគ្គិសនីមានម៉ាស៊ីនសរុបចំនួន ០៤គ្រឿង មានអានុភាពតម្លើងសរុបចំនួន 1.00 MVA រួមមាន ៖ | 1. The Plant consists of 4 diesel generator Units with total installed capacity of 1.00 MVA: |

| | |
|---|---|
| -ម៉ាស៊ីនភ្លើងអានុភាពតម្លើង 250 kVA ចំនួន ៤គ្រឿង | -4 diesel engines with installed capacity of 250 kVA each |
| ២. ប្រេងឥន្ធនៈប្រើប្រាស់សម្រាប់ដំណើរការរោងចក្រអគ្គិសនី គឺប្រេងដេស្សែល LDO ។ | 2. The normal fuel for the operation of the Power Plant shall be Light Distillate Oil (LDO). |
| **គ ការស្នើសុំផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម** | **C. Request of changing or adding generating facility** |
| ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម ឧបសម្ព័ន្ធទី១នេះត្រូវធ្វើការកែសម្រួល ដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្មនោះ។ | Under this license, if the licensee intends to request the changing or the additional generation facility then the licensee shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to change or to add generation facility, this schedule 1 shall be revised and attached with that authorization. |